ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.១០០.......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារចម្រុះរវាង
## អគ្គនាយកដ្ឋានពន្ធដារ និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារចម្រុះអគ្គនាយកដ្ឋានពន្ធដារ និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលមានសមាសភាពដូចខាងក្រោម÷

**ក-អគ្គនាយកដ្ឋានពន្ធដារ÷**

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយដ្ឋានពន្ធដារ | សហប្រធាន |
| ២. | ឯកឧត្តម **វ៉ាន់ ពុទ្ធិពល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៣. | ឯកឧត្តម **ម៉ិញ បានកុសល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៤. | ឯកឧត្តម **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥. | លោកជំទាវ **ម៉ិន នារី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦. | លោក **អេង គនា** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | សមាជិក |
| ៧. | លោក **ឌី សុខុន** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម | សមាជិក |
| ៨. | លោក **រៀម រដ្ឋា** | ប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ៩. | លោក **សេង ជាសិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ | លេខាធិការ |
| ១០. | លោក **កែវ ម៉ច់តា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ | សមាជិក |
| ១១. | លោក **ជុំ សុលីវណ្ណ** | ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ | សមាជិក |

**ខ- សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល**

| | | | |
|---|---|---|---|
| ១. | លោក **សឿន សារឿន** | នាយកប្រតិបត្តិ នៃគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា | សហប្រធាន |
| ២. | លោកស្រី **តាំង ស៊ូហ៊ាក** | នាយិកាហិរញ្ញវត្ថុ និងសេវាគាំទ្រ នៃអង្គការទស្សនៈពិភពលោក | អនុប្រធាន |
| ៣. | លោកស្រី **លឹម សុលីន** | នាយិកាប្រចាំប្រទេស នៃអង្គការអុកស្វាម | អនុប្រធាន |
| ៤. | លោក Adam Glen | អ្នកស្ម័គ្រចិត្តផ្នែកពន្ធដារ នៃអង្គការគណៈកម្មាធិការ សហប្រតិបត្តិការដើម្បីកម្ពុជា | សមាជិក |
| ៥. | លោកស្រី **ម៉ាត ម៉ុណ្ណារី** | នាយិកាប្រតិបត្តិ នៃអង្គការបន្ទាយស្រី | សមាជិក |
| ៦. | លោកស្រី **អស់ សុនិតា** | នាយិកាប្រតិបត្តិ នៃអង្គការយែនឌ័រ និងអភិវឌ្ឍនៅកម្ពុជា | សមាជិក |
| ៧. | លោក **ទឹម វ៉ា** | នាយកប្រតិបត្តិ នៃអង្គការគណៈកម្មាធិការសម្របសម្រួលសកម្មភាពសុខភាព | សមាជិក |
| ៨. | លោក **រុន សារ៉ាយ** | នាយកប្រតិបត្តិ នៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា | សមាជិក |
| ៩. | លោកស្រី **ហ៊ុន បូរមី** | នាយិកាប្រចាំប្រទេស នៃអង្គការអាកសិនអេដ | សមាជិក |
| ១០. | លោក **ស៊ិន ឡុង** | នាយកជាន់ខ្ពស់ផ្នែកប្រតិបត្តិការ នៃអង្គការតម្លាភាពកម្ពុជា | សមាជិក |
| ១១. | លោក **តឹក វណ្ណារ៉ា** | នាយកប្រតិបត្តិ នៃអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា | សមាជិក |
| ១២. | លោកស្រី **ឌៀង សុគា** | ប្រធានផ្នែកហិរញ្ញវត្ថុ នៃអង្គការអភិវឌ្ឍន៍ទឹកនិងទីផ្សារជនបទ | សមាជិក |

១៣. លោក **ហម ស៊ុនរិទ្ធិ** ប្រធានផ្នែកការពារ (ក្តី) នៃអង្គការសង់ត្រាល់ សមាជិក
១៤. លោក **ស៊ុន ពេញ** នាយកប្រតិបត្តិ នៃអង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជា សមាជិក
១៥. លោកស្រី **ចេត ចរិយា** នាយិកាប្រតិបត្តិ នៃអង្គការស្តារកម្ពុជា សមាជិក
១៦. លោក **ជំរា រិទ្ធ** នាយកប្រតិបត្តិ នៃអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល សមាជិក
១៧. លោក **មាស យាង** នាយកប្រតិបត្តិ នៃអង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។ សមាជិក

**ប្រការ ២._**

ក្រុមការងារចម្រុះនេះ មានភារកិច្ចក្នុងភាពជាដៃគូ អនុវត្តនូវការងារដូចខាងក្រោម÷

- ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធដែលកំពុងមានជាធរមាន
- ពិនិត្យ និងបកស្រាយឱ្យបានត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពន្ធដារ ដែលមានភាពមិនច្បាស់លាស់ ព្រមទាំងកែសម្រួល និងបង្កើតបទប្បញ្ញត្តិមួយចំនួនតាមការចាំបាច់
- ពិនិត្យបញ្ហានានាទាក់ទងនឹងការអនុវត្តវិធាន និងនីតិវិធីសារពើពន្ធ សំដៅបង្កើតជំនឿទុកចិត្តរបស់អ្នកជាប់ពន្ធ និងធានាដល់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារឱ្យបានរលូននិងមានប្រសិទ្ធភាពខ្ពស់
- ពិនិត្យ និងដោះស្រាយបញ្ហាអាដហុក (Ad hoc) ដែលពាក់ព័ន្ធនឹងពន្ធដារ
- ពង្រឹងការអនុវត្តក្រមសីលធម៌វិជ្ជាជីវៈទីប្រឹក្សាច្បាប់ គណនេយ្យ សវនកម្មឯករាជ្យ និងភ្នាក់ងារផ្តល់សេវាពន្ធដារ។

**ប្រការ ៣._**

សហប្រធាននៃក្រុមការងារនេះ ត្រូវដឹកនាំកិច្ចប្រជុំរាល់បីខែម្តង ឬក្នុងពេលវេលាណាមួយតាមការចាំបាច់។ ក្នុងករណីសហប្រធានណាមួយអវត្តមាន សហប្រធាននោះ អាចចាត់តាំងអនុប្រធាន ឬតំណាងរបស់ខ្លួនដើម្បីចូលរួមដឹកនាំកិច្ចប្រជុំ។

**ប្រការ ៤._**

សហប្រធាន អនុប្រធាន និងសមាជិកនៃក្រុមការងារចម្រុះរវាងអគ្គនាយកដ្ឋានពន្ធដារ និងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដូចមានចែងក្នុងប្រការ ១ នៃប្រកាសនេះ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ១០រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ